**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអភិបូជានៅកោះនរា**
**ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៨**
*ការប្រកាសដំណឹងល្អជាកិត្តិយសរបស់យើង*

អត្ថបទទី១៖ យប ៧,១-៤.៦-៧
អត្ថបទទី២៖ ១ករ ៩,១៦-១៩.២២-២៣
ដំណឹងល្អ៖ មក ១,២៩-៣៩

បងប្អូនជាទីស្រឡាញ់!

អត្ថបទទីពីរ ដែលសន្តប៉ូលផ្តល់សក្ខីភាពយ៉ាងពិសេស "**ខ្ញុំមិនត្រូវអួតថា ការប្រកាសដំណឹងល្អជាកិត្តិយសរបស់ខ្ញុំនោះទេ ព្រោះជាភារកិច្ចមួយដែលខ្ញុំត្រូវតែធ្វើដោយខានមិនបាន ប្រសិនបើខ្ញុំមិនប្រកាសដំណឹងល្អទេ សុំឲ្យខ្ញុំវេទនាទៅចុះ ប្រសិនបើខ្ញុំស្ម័គ្រចិត្តប្រកាសដំណឹងល្អដោយខ្លួនឯង ខ្ញុំត្រូវតែទទួលបៀវត្ស**"។ ខ្ញុំមិនត្រូវការខ្មាស់ ផ្ទុយទៅវិញប្រសិនបើខ្ញុំមិនប្រកាសដំណឹងល្អខ្ញុមខ្មាស់ណាស់ ប្រសិនបើខ្ញុំមិនចេះចែកដំណឹងល្អអំពីព្រះយេស៊ូដល់បងប្អូនឯទៀតៗ ខ្ញុំខ្មាស់គេណាស់ ដោយសារកិត្តិយសរបស់ខ្ញុំ តួនាទីរបស់ខ្ញុំ ភារកិច្ចរបស់ខ្ញុំ ធម្មជាតិនៃជីវិតរបស់ខ្ញុំ គឺណែនាំឲ្យមនុស្សយ៉ាងច្រើនស្គាល់ព្រះយេស៊ូ។ យើងត្រូវតែប្រកាសដំណឹងល្អ អំពីព្រះយេស៊ូដល់បងប្អូនឯទៀតៗ នេះជាភារកិច្ចរបស់យើងជាគ្រីស្តបរិស័ទ។ ដូចសន្តប៉ូល យើងជាគ្រីស្តទូតដើម្បីចែករំលែក អំពីដំណឹងល្អអំណរសប្បាយសេចក្តីសង្ឃឹមដែលព្រះយេស៊ូប្រទានឲ្យយើង។

ថ្ងៃនេះព្រះយេស៊ូកំពុងដើរជាមួយក្រុមគ្រីស្តទូត គាត់ទៅដល់ភូមិលោកសិលាដែលម្តាយក្មេករបស់លោកសិលាកំពុងឈឺលើគ្រែ។ ព្រះយេស៊ូ ណែនាំឲ្យក្រុមគ្រីស្តទូតមើលរបៀបព្រះអង្គ ដើម្បីពេលក្រោយពួកគេធ្វើតាម។ នៅពេលព្រះយេស៊ូដឹងថា ម្តាយក្មេកលោកសិលាឈឺ ព្រះអង្គបានយាងចូលទៅជិត ហើយចាប់ដៃគាត់ឲ្យក្រោកឡើង ភ្លាមនោះគាត់ក៏បានជាហើយបម្រើភ្ញៀវ។ ព្រះយេស៊ូចូលនៅក្នុងផ្ទះរបស់ម្តាយក្មេកលោកសិលា ព្រះយេស៊ូទៅជិតគាត់ ព្រះយេស៊ូចាប់ដៃគាត់ ព្រះយេស៊ូជាគ្រូគង្វាលដ៏សប្បុរស។ ដើម្បីប្រកាសដំណឹងល្អ ឲ្យយើងចូលនៅក្នុងផ្ទះបងប្អូន ដើម្បីសួរសុខទុក្ខ ដើម្បីស្តាប់ទុក្ខលំបាក ដើម្បីអង្គុយលេង ដើម្បីលើកទឹកចិត្ត ដើម្បីណែនាំអប់រំយុវជនយើងឲ្យរកឃើញផ្លូវត្រឹមត្រូវនៅក្នុងជីវិត។ យើងមិនគិតតែអ្នកជំងឺដែលមានជំងឺផ្លូវកាយ យើងត្រូវការគិតដល់បងប្អូនទាំងអស់ ទាំងកុមារ ទាំងយុវជន ទាំងឪពុកម្តាយ ទាំងយាយតា។ ចូលនៅក្នុងផ្ទះ សួរសុខទុក្ខដើម្បីណែនាំឲ្យអំណរសប្បាយនិងពន្លឺរបស់ព្រះយេស៊ូយាងចូល។ នៅពេលយើងជាគ្រី

ស្គបរិស័ទ ទៅសួរសុខទុក្ខបងប្អូនដែលកំពុងមានទុក្ខលំបាក អាចណែនាំឲ្យបងប្អូនរបស់យើងមានកម្លាំងនិងជីវិតសារជាថ្មី។

"**លុះដល់ល្ងាច គេនាំអ្នកជំងឺនិងមនុស្សខ្មោចចូលទាំងអស់មកគាល់ព្រះយេស៊ូ**" ព្រះយេស៊ូក៏បានណែនាំឲ្យអ្នកជំងឺទាំងអស់បានជាសះស្បើយ "**ព្រះអង្គបានដេញខ្មោចជាច្រើនចេញពីមនុស្សផង**"។ ព្រះយេស៊ូបន្តទទួលយើងសព្វថ្ងៃ ព្រះយេស៊ូណែនាំឲ្យយើងមានកម្លាំងជានិច្ច "**ប្រសិនបើយើងផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ ព្រះអង្គណែនាំឲ្យយើងមានកម្លាំងណាស់ដើម្បីតស៊ូនៅក្នុងជីវិតរបស់យើង និងដើម្បីធ្វើជាគ្រូគង្វាលដ៏សប្បុរស**"។

ព្រឹកឡើងនៅយប់នៅឡើយ ព្រះយេស៊ូបានយាងចេញពីផ្ទះទៅកន្លែងមួយស្ងាត់ដើម្បីអធិដ្ឋាន ដើម្បីបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់។ ឲ្យយើងយកពេលវេលាដើម្បីអធិដ្ឋាន ដើម្បីទូលអង្វរទៅព្រះបិតា ដើម្បីអរព្រះគុណព្រះជាម្ចាស់ ដើម្បីស្ដាប់ព្រះបន្ទូលបំភ្លឺយើង...។ គ្រីស្គបរិស័ទដែលនៅឆ្ងាយពីព្រះយេស៊ូ មិនអាចទៅជាគ្រីស្គបរិស័ទដែលប្រកាសដំណឹងល្អបានទេ។

ក្រោយមកព្រះយេស៊ូណែនាំក្រុមគ្រីស្គទូតថា "**យើងនាំគ្នាទៅភូមិឯទៀតៗដែលនៅក្បែរនេះ ដើម្បីឲ្យខ្ញុំប្រកាសដំណឹងល្អនៅទីនោះដែរ ដ្បិតខ្ញុំចេញមកដើម្បីបំពេញការងារនេះឯង**"។ ព្រះយេស៊ូ បានបន្តទៅភូមិនានាដើម្បីប្រកាសដំណឹងល្អ ឲ្យគេលឺដើម្បីបានទទួលជីវិតថ្មីដែរ។

នៅពេលយើងទៅសួរសុខទុក្ខនៅផ្ទះ នៅពេលយើងបានស្វាគមន៍បងប្អូន នៅពេលយើងយកពេលវេលាដើម្បីអធិដ្ឋាន យើងដឹងថាយើងបានទៅប្រកាសដំណឹងល្អដល់ភូមិនានា។ យើងត្រូវការបង្ហាញអំពីសក្ខីភាព អំពីយើងជាគ្រីស្គបរិស័ទដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ដែលចេះសម្រុះសម្រួលនៅពេលមានបញ្ហា។ សព្វថ្ងៃ យើងមានប្រជាជនដែលមកនៅក្បែរកន្លែងយើងជាច្រើន ដែលពួកគាត់ប្រហែលចង់ស្គាល់ព្រះយេស៊ូដែរ ឲ្យយើងរៀងៗខ្លួនទៅជាជួងមួយសម្រាប់បងប្អូនឯទៀតៗឲ្យគេលឺសម្លេង និងព្រះសូរសៀងរបស់ព្រះជាម្ចាស់។ នៅជុំវិញយើងមានអ្នកក្រីក្រយ៉ាងច្រើន ដែលទន្ទឹងរង់ចាំការលើកទឹកចិត្តនិងកម្លាំងកាយកម្លាំងចិត្តពីយើងជាគ្រីស្គបរិស័ទ ជាសាវ័ករបស់ព្រះយេស៊ូ។

ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ សន្តប៉ូលណែនាំឲ្យយើងមិនខ្មាស់ក្នុងការប្រកាសដំណឹងល្អ ណែនាំឲ្យយើងមើលព្រះយេស៊ូទៅសួរសុខទុក្ខតាមផ្ទះ ព្រះយេស៊ូទៅប្រកាសដំណឹងល្អ ព្រះយេស៊ូយកពេលវេលាដើម្បីអធិដ្ឋាន ព្រះយេស៊ូណែនាំឲ្យយើងចេញ

ពីកន្លែងមួយទៅកន្លែងមួយដើម្បីប្រកាសដំណឹងល្អគ្រប់ទីកន្លែង ព្រោះយើងជាគ្រីស្ទបរិស័ទ យើងជាគ្រីស្ទទូតដូចសន្តប៉ូល ការប្រកាសដំណឹងល្អជាកិត្តិយសរបស់យើង ជាភារកិច្ចដែលយើងត្រូវតែធ្វើដោយខានមិនបាន។ អាម៉ែន៕